## ស្ថានទម្ងន់ទោស (aggravating circumstances)

ស្ថានទម្ងន់ទោស ជាធាតុផ្សំ ពាក់ព័ន្ធនឹងបទល្មើស ឬជនត្រូវចោទ ដែលនាំឲ្យមានការបង្កើតទោស។ ទាំងនេះវាពាក់ព័ន្ធនឹង កាលៈទេសៈ (circumstances) និងកត្តា (factors) ដែលមិនទាន់ភាពច្បាស់លាស់ ថាតើមួយណាមានទម្ងន់ជាង។

កត្តា ឬកាលៈទេសៈទាំងនោះមានច្រើន ដែលនឹងត្រូវពិចារណាជាសត្យានុម័ត (objective) ទាក់ទងនឹងបទល្មើស (offense) ឬជាអត្តនោម័ត (subjective) aggravating circumstances ទាក់ទងនឹងជនត្រូវចោទ (defendant)។ ទី១ មានដូចជា វិសាលភាពនៃបទឧក្រិដ្ឋ រយៈពេលប្រព្រឹត្ត ចរិតហិង្សានៃអំពើ ការបំពានអំណាច (abuse of authority) ភាពងាយរងគ្រោះនៃជនរងគ្រោះ អាយុ និងចំនួន ជនរងគ្រោះ។

សម្រាប់ subjective AC មានដូចជា ចេតនារើសអើង ប្រវត្តិវិជ្ជាជីវៈនៃជនត្រូវចោទ តួនាទីក្នុងការប្រព្រឹត្ត ចរិតនៃជនល្មើស ប្រវត្តិជាប់ទោសពីមុន។

បទប្បញ្ញត្តិ ពាក់ព័ន្ធស្ថានទម្ងន់ ត្រូវតែពិចារណាដល់គោលការណ៍នីត្យានុកូលភាព និង ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 235-236)។